ក្រសួងយុត្តិធម៌សហរដ្ឋអាមេរិក
នាយកដ្ឋានសិទ្ធិពលរដ្ឋ

ក្រសួងអប់រំសហរដ្ឋអាមេរិក
ការិយាល័យសិទ្ធិពលរដ្ឋ

# ការប្រឈមមុខនឹងការយាយីពាក់ព័ន្ធនឹងជំងឺកូវីដ-19 នៅសាលារៀន

## ប្រភពធនធានមួយសម្រាប់គ្រួសារសិស្ស

ការយាយី និងការរើសអើងផ្សេងទៀត ដែលកើតចេញពីភាពលម្អៀង និងភាពភ័យខ្លាចគ្មានមូលដ្ឋានអំពីមេរោគកូរ៉ូណា (ជំងឺកូវីដ-19) គឺជាការខុសឆ្គង ហើយអាចមានផលប៉ះពាល់ខូចខាតមកលើសិស្ស និងគ្រួសារសិស្ស។

ក្នុងអំឡុងវិបត្តិជំងឺរីករាលដាលជាសាកលនេះ ព័ត៌មានមិនពិត និងសេចក្ដីថ្លែងព្យាបាតអំពីសហគមន៍ជនជាតិអាមេរិកដើមកំណើតនៅអាស៊ី និងកោះប៉ាស៊ីហ្វិក (Asian American and Pacific Islander, AAPI) បានធ្វើឲ្យកើនឡើងនូវសកម្មភាពនានាដែលមិនអាចអត់ឱនបាននៅទូទាំងប្រទេស -- ដូចជា ការយាយីដោយប្រើសម្ដី និងអំពើហិង្សា។ នៅតាមសាលារៀនទូទាំងប្រទេស សិស្ស AAPI បានរាយការណ៍អំពីសកម្មភាពសម្លុត និងយាយីពីសំណាក់មិត្តរួមថ្នាក់ ដោយសារតែជាតិសាសន៍ ឬដើមកំណើតជាតិរបស់ខ្លួន ដែលរួមបញ្ចូល ជាតិពន្ធ ពូជពង្ស និងភាសា។

សាលាមតេយ្យ និងមធ្យមសិក្សារបស់រដ្ឋ ក៏ដូចជាមហាវិទ្យាល័យ និងសាកលវិទ្យាល័យ ត្រូវទទួលខុសត្រូវធ្វើការស៊ើបអង្កេត និងដោះស្រាយការរើសអើង រាប់ទាំង ការយាយី ការតម្រង់លើសិស្ស ផ្អែកលើជាតិសាសន៍ ឬដើមកំណើតជាតិ។ នៅពេលដែលសាលារៀនខកខានក្នុងការចាត់វិធានការផ្សេងៗដែលសមរម្យ ផ្នែកឱកាសអប់រំនៃនាយកដ្ឋានសិទ្ធិពលរដ្ឋ (CRT) ក្នុងក្រសួងយុត្តិធម៌សហរដ្ឋអាមេរិក និងការិយាល័យសិទ្ធិពលរដ្ឋ (OCR) ក្នុងក្រសួងអប់រំសហរដ្ឋអាមេរិក អាចជួយបាន តាមរយៈការអនុវត្តច្បាប់សហព័ន្ធ ដែលការពារសិស្សពីការរើសអើង។

## ឧទាហរណ៍នៃប្រភេទហេតុការណ៍ ដែល CRT និង OCR អាចធ្វើការស៊ើបអង្កេត៖

សិស្សសាលាមធ្យមសិក្សា ថតវិដេអូខ្លួនឯង ពេលស្រែកពាក្យ “virus spreader!” (អ្នកចម្លងមេរោគ!) ទៅកាន់មិត្តរួមថ្នាក់ជាជនជាតិអាមេរិកដើមកំណើតអាស៊ី នៅក្នុងថ្នាក់រៀន ហើយបានបង្ហោះវិដេអូនៅលើបណ្ដាញសង្គម។ បុគ្គលិករដ្ឋបាលសាលារៀនបានដឹងអំពីវីដេអូនេះ ប៉ុន្តែបដិសេធមិនធ្វើការស៊ើបអង្កេត ឬចាត់វិធានការណាមួយ ដើម្បីការពារសិស្សអាមេរិកដើមកំណើតអាស៊ីពីការយាយីបន្តទៀតនៅសាលារៀនឡើយ។

សិស្សវិទ្យាល័យបង្ហោះដោយមិនបញ្ចេញឈ្មោះលើកម្មវិធីជជែក (chat windows) ក្នុងអំឡុងថ្នាក់សិក្សាពីចម្ងាយថា មិត្តរួមថ្នាក់ជាជនជាតិអាមេរិកដើមកំណើតអាស៊ីបានបំផ្លិចបំផ្លាញឆ្នាំសិក្សាទាំងមូល ដោយនាំវីរុសចិន (“China Virus”) មកក្នុងសហគមន៍។ គ្រូបង្រៀនអាចមើលឃើញការជជែកនោះ ប៉ុន្តែមិនបានដោះស្រាយទេ ឬមិនបានកម្រិតលើការបង្ហោះដោយមិនបញ្ចេញឈ្មោះនោះទេ។ សិស្សអាមេរិកដើមកំណើតអាស៊ី បិទវីដេអូរបស់ខ្លួន ដើម្បីកុំឲ្យសិស្សដទៃទៀតអាចមើលឃើញខ្លួន ប៉ុន្តែការជជែកនៅតែបន្ត។

ពេលត្រៀមរៀបចំត្រឡប់មកការសិក្សាដោយផ្ទាល់វិញ នាយកសាលាបឋមសិក្សាសួរមាតាបិតាសិស្សអាមេរិកដើមកំណើតអាស៊ីអំពីការធ្វើដំណើរទៅចិន ទំនាក់ទំនងគ្រួសារនៅអាស៊ី និងទាមទារភស្តុតាងតេស្តអវិជ្ជមានជំងឺកូវីដ-19 មុនពេលសិស្សអាចចុះឈ្មោះបាន។ មណ្ឌលសាលាមិនស្នើសុំព័ត៌មាននេះពីសិស្សដែលគ្មានពូជពង្សអាស៊ីឡើយ។

នៅសាលាមធ្យមសិក្សា សិស្សនៅអាហារដ្ឋានធ្វើអត្ថាធិប្បាយអំពីការពាក់ម៉ាស់ពីរជាន់ នៅពេលដែលសិស្សអាមេរិកដើមកំណើតអាស៊ីនៅក្បែរ។ ពួកគេក៏ចំអកដាក់សិស្សអាមេរិកដើមកំណើតអាស៊ី ដែលនិយាយភាសាកំណើតជាមួយគ្នា នៅចំពោះមនុស្សពេញវ័យដែលឃ្លាំមើល ពេលអាហារថ្ងៃត្រង់។ ដើម្បីជៀសវាងជម្លោះ សិស្សអាមេរិកដើមកំណើតអាស៊ីចាប់ផ្ដើមអង្គុយនៅតុអាហារថ្ងៃត្រង់ផ្សេងវិញ។

បុគ្គលិករដ្ឋបាលទទួលបន្ទុកកន្លែងស្នាក់នៅរបស់មហាវិទ្យាល័យប្រាប់សិស្សអាមេរិកដើមកំណើតអាស៊ីឲ្យពិចារណាកន្លែងស្នាក់នៅដែលនៅក្រៅបរិវេណមហាវិទ្យាល័យ ជាជាងសយនដ្ឋានរបស់មហាវិទ្យាល័យ ដោយពន្យល់ថា សិស្សដទៃទៀតអាចមានចិត្តរសាប់រសល់ពេលដែលរស់នៅក្នុងបន្ទប់សយនដ្ឋាន ជាមួយសិស្សអាមេរិកដើមកំណើតអាស៊ី រហូតទាល់តែអ្នកគ្រប់គ្នាបានចាក់វ៉ាក់សាំងរួច។

ក្រសួងយុត្តិធម៌សហរដ្ឋអាមេរិក
នាយកដ្ឋានសិទ្ធិពលរដ្ឋ

ក្រសួងអប់រំសហរដ្ឋអាមេរិក
ការិយាល័យសិទ្ធិពលរដ្ឋ

# ចុះបើសិស្សជួបប្រទះ ការរើសអើងនៅសាលារៀន?

ប្រសិនបើអ្នកជឿជាក់ថា សិស្សម្នាក់ត្រូវបានគេប្រតិបត្តិមកលើ ដោយមិនត្រឹមត្រូវ —ឧទាហរណ៍ ត្រូវបានគេប្រតិបត្តិមកលើខុសពីអ្នកដទៃ ត្រូវបានគេឃាយី សម្លុត ឬសងសឹក —ដោយសារជាតិសាសន៍ ឬដើមកំណើតជាតិ មានវិធានការជាច្រើនដែលអ្នកអាចអនុវត្តបាន៖

1. **ជូនដំណឹងប្រាប់អ្នកដឹកនាំសាលារៀន** (ឧទាហរណ៍ នាយកសាលារៀន ឬបុគ្គលិកផ្នែកកិច្ចការសិស្ស) ភ្លាមៗ។ ប្រសិនបើអ្នកមិនបានទទួលជំនួយដែលអ្នកត្រូវការទេ ត្រូវដាក់ពាក្យបណ្តឹងផ្លូវការនៅសាលារៀន មណ្ឌលសាលា មហាវិទ្យាល័យ ឬសាកលវិទ្យាល័យ។ រក្សាទុកជាឯកសារនូវការឆ្លើយតប ដែលអ្នកបានទទួល។

2. **កត់ត្រាសេចក្តីលម្អិត** អំពីហេតុការណ៍ដែលបានកើតឡើង ទីកន្លែង និងពេលវេលាកើតហេតុការណ៍ បុគ្គលពាក់ព័ន្ធ និងឈ្មោះសាក្សី។ ធ្វើបែបនេះចំពោះរាល់ការរើសអើងទាំងអស់ និងរក្សាទុកច្បាប់ចម្លងនៃឯកសារពាក់ព័ន្ធ ឬព័ត៌មានផ្សេងទៀត។

3. ស្នើឲ្យសាលារៀន ឬមហាវិទ្យាល័យ/សាកលវិទ្យាល័យធ្វើការបកប្រែឯកសារ (ដូចជា ទម្រង់ពាក្យបណ្តឹង) និងសារផ្សេងៗជាភាសាដែលអ្នកយល់។ **ស្នើសុំអ្នកបកប្រែផ្ទាល់មាត់ ប្រសិនបើអ្នកត្រូវការជំនួយ** ដើម្បីជជែកជាមួយបុគ្គលិកសាលារៀនដោយប្រើប្រាស់ភាសាផ្សេងក្រៅពីភាសាអង់គ្លេស។

4. ប្រសិនបើសាលារៀន ឬមហាវិទ្យាល័យ/សាកលវិទ្យាល័យមិនចាត់វិធានការ ដើម្បីដោះស្រាយពាក្យបណ្តឹងរបស់អ្នកទេ ឬប្រសិនបើការរើសអើងនៅបន្តកើតមាន **ត្រូវពិចារណាដាក់ពាក្យបណ្តឹង** នៅនាយកដ្ឋានសិទ្ធិពលរដ្ឋនៃក្រសួងយុត្តិធម៌សហរដ្ឋអាមេរិក នៅវេបសាយ civilrights.justice.gov ឬក៏នៅការិយាល័យសិទ្ធិពលរដ្ឋនៅក្រសួងអប់រំសហរដ្ឋអាមេរិក នៅវេបសាយ https://www2.ed.gov/ocr/complaintintro.html (ដើម្បីដាក់ពាក្យបណ្តឹងជាភាសាអង់គ្លេស) ឬ https://www2.ed.gov/about/offices/list/ocr/docs/howto.html (ដើម្បីដាក់ពាក្យបណ្តឹងជាភាសាផ្សេងទៀត)។

*“គ្មានជនណាម្នាក់នៅសហរដ្ឋអាមេរិក ត្រូវរស់នៅក្នុងភាពភ័យខ្លាច រងគ្រោះ ដោយសារតែអត្តសញ្ញាណ ជំនឿសាសនា កន្លែងកំណើតរបស់ពួកគេ ឬបុគ្គលដែលពួកគេស្រឡាញ់ឡើយ។ ភាពចម្រុះសាសន៍ មានសារៈសំខាន់ណាស់ចំពោះយើងជាប្រទេសមួយ ហើយក្រសួងយុត្តិធម៌ប្តេជ្ញាចិត្តធ្វើឲ្យជនណាដែលបំពានសិទ្ធិពលរដ្ឋរបស់អ្នកដទៃត្រូវទទួលខុសត្រូវ”។*

**-Pamela Karlan, ឧបការីរងរបស់អគ្គរដ្ឋអាជ្ញា ទទួលបន្ទុកសិទ្ធិពលរដ្ឋ ក្រសួងយុត្តិធម៌**

*“ការរើសអើងជាតិសាសន៍ និងការស្អប់ជនបរទេស មិនត្រូវកើតមាននៅអាមេរិកឡើយ។ ភាពចម្រុះសាសន៍ គឺជាចំណុចខ្លាំងអស្ចារ្យរបស់ប្រទេសយើង ហើយការិយាល័យសិទ្ធិពលរដ្ឋរបស់ក្រសួងអប់រំ ប្តេជ្ញាចិត្តប្រយុទ្ធប្រឆាំងការរើសអើង និងធ្វើការដើម្បីអនាគតកាន់តែមានសមធម៌បន្ថែមទៀតសម្រាប់សិស្សរបស់ប្រទេសយើង”។*

**-Suzanne B. Goldberg, ឧបការីស្តីទីរបស់រដ្ឋមន្ត្រី ទទួលបន្ទុកសិទ្ធិពលរដ្ឋ ក្រសួងអប់រំ**

